# ការសំភាសន៍របស់បងស្រី ក្រូច គន្ធា

ក ៖ អ្នកសំភាសន៍មាន អ៊ុំ កន្និកា ខ ៖ អ្នកដែលត្រូវគេសំភាសន៍ ក្រូច គន្ធា

ក៖ ជំរាបសួរនាងខ្ញុំឈ្មោះ អ៊ុំ កន្និកា ហើយ ជាដំបូងខ្ញុំសូមថ្លែងអំណរគុណដល់បងស្រីដែលគាត់បានចំណាយពេលវេលាយ៉ាងមានតម្លៃរបស់គាត់ដើម្បីផ្តល់អោយខ្ញុំនូវការសំភាសន៍ទាក់ទងទៅនិងជីវប្រវត្តិរបស់គាត់ផងដែរ៕ហើយការសំភាសន៍នេះគឺធ្វើឡើងដោយសាលាសកលវិទ្យាល័យប៊ីវ៉ាយយ៉ូ(BYU) ដោយសារតែសកលវិទ្យាល័យយើងចង់ថែរក្សានូវជីវប្រវត្តិរបស់ជីដូនជីតាក៏ដូចជារបងស្រីដើម្បីទុកដល់កូនចៅជំនាន់ក្រោយដើម្បីស្តាប់ដូចជាទទួលបានបទពិសោធន៍ល្អៗផ្សេងៗផងដែរ៕ហើយបន្ទាប់ពីការសំភាសន៍នេះចប់ក៏ពួកយើងដូចជាសុំការអនុញ្ញាតពីបងស្រីដើម្បីយើងនិងដាក់ចូលសំលេងរបស់គាត់ទៅក្នុងគេហទំព័រដែលមានឈ្មោះថា"(www.cambodia.noralhistories.by.edu)"ផងដែរហើយយើងនិងទៅជួបគាត់ទាំងអស់គ្នាដោយកាលបរិច្ឆេតគឺនៅថ្ងៃទី20 ខែ2ឆ្នាំ2018ហើយទីកន្លែងគឺនៅភូមិព្រែកទាល់ហើយយើងនិងទៅជួបគាត់ទាំអស់គ្នា... ជំរាបសួរបងស្រី....!

ខ៖ ចាំ...ជំរាបសួរ!

ក៖ តើបងស្រីមានឈ្មោះអ្វីដែរ?

ខ៖ ខ្ញុំឈ្មោះ គន្ធា....៕

ក៖ គន្ធា ណោះបងណោះ?

ខ៖ ចាំ...!

ក៖ ដូចជាតើបងស្រីអឺ..មានឈ្មោះហៅក្រៅទេ?

ខ៖ អត់ផង...!

ក៖ អញ្ចឹងឈ្មោះកាលនៅពីក្មេងក៏ឈ្មោះបែបនិងដែរ?

ខ៖ ចាំ...ឈ្មោះបែបនិងដែរ៕

ក៖ ចាស...ដូចជាបងស្រីមានអាយុប៉ុន្មានហើយ?

ខ៖ ខ្ញុំឆ្នាំអឺក....ឆ្នាំសាមមួយហើយ...!

ក៖ សាមសិបមួយហើយអ្ហោះបង...?

ខ៖ ចា៎....!

ក៖ តើបងកកើតឆ្នាំណាដែរ?តើបងចាំទេ?

ខ៖ ខ្ញុំអត់បានចាំហ៎ង..អូនឆ្នាំ៕

ក៖ ចុះដូចជាឆ្នាំ ជូត ឆ្លូវ ខាល អីបងចាំទេ?

ខ៖ ខ្ញុំឆ្នាំ រោង...!

ក៖ រោង ណោះបងណោះ...?

ខ៖ ចា៎....!

ក៖ តើទីកន្លែងដែលបងកើតវិញនៅទីណាដែរបង?

ខ៖ នៅអឺ...ខេត្តកំពង់ចាម នៅ....

ក៖ ចុះភូមិស្រុកវិញ...?

ខ៖ នៅភូមិ ស្រែកយំ ឃុំព្រៃឈរ ស្រុកព្រៃឈរ ខេត្តកំពង់ចាម៕

ក៖ អ៎...ចា៎ ចុះបងមានបងប្អូនប៉ុន្មាននាក់ដែរ?

ខ៖ ខ្ញុំមាន ប្រាំមួយនាក់...!

ក៖ អ៎..ប្រាំមួយនាក់..!

ខ៖ ចា៎..! ប្រុសមួយស្រីប្រាំ...

កៈ ប្រុសមួយ ស្រីប្រាំ..៕ចុះតើបងអាចរៀបរាប់ទក់ទងទៅនិងឈ្មោះរបស់ពួកគាត់ម្តងមួយៗចាប់ពីបងច្បងម៉ោបានទេ?

ខៈអឺ...និងហើយ អឺ...កូនបងអឺ..ឈ្មោះសុភា ហើយកូនទីពីឈ្មោះក្រួចសម្ផស្ស ហើយទីបីឈ្មោះក្រួច រឿន ហើយបួនគឺញ៉ុមឈ្មោះក្រួច គន្ធា ហើយប្អូនញ៉ុមមួយទៀតឈ្មោះក្រួច ស្រស់ហើយមួយទៀតក្រួចរក្សា៕

កៈ អ៎...ចាំ..ចុះនៅរៀនប៉ុន្មានហើយធ្វើការប៉ុន្មាននាក់ដែរ?

ខៈ អឺ..ចាំសធ្វើការអស់ហើយ៕

កៈ ធ្វើការទាំងអស់តែម្តង...?

ខៈ ចាំ...ឈប់រៀនអស់ហើយ..!

កៈ ចុះប្អូនពៅក៏ធ្វើការដែរ?

ខៈ ចាំ..គាត់ឈប់រៀនគាត់ចូលធ្វើការយកលុយជួយម៉ែ៕

កៈ តើបងជាកូនទីប៉ុន្មានដែរ?

ខៈ ចាំ..មើល...ញ៉ុមទីបួន..!

កៈ ចុះកូនច្បងគាត់មានមុខរបរអ្វីដែរ?

ខៈ ចាំ..គាត់ធ្វើសិនទ្រី...!

កៈ អ៎...ខាងសំរាម...!

ខៈ ចាំ...សំរាម.

កៈ ចុះបន្ទាប់មកទៀតធ្វើខាងអីគេដែរ?

ខៈ បងស្រីញ៉ុមខាងមួយទៀត អឺ គាត់យកផ្លែឈើមកលក់៕

កៈ គាត់អ្នកលក់ផ្លែឈើ...!

ខ៖ ចាំ....!

ក៖បន្ទាប់មកទៀតបង?

ខ៖ បន្ទាប់មកទៀតបងញ៉ុមគាត់អឺ...ពីមុនម៉ោគាត់បើកឡាន..

ក៖ អ៎...ចាំអ្នកបើកឡាន...ចុះបងស្រីវិញ?

ខ៖ ញ៉ុមនៅផ្ទះ ហើយអោយប្តីញ៉ុម្ញើសន្តិសុខញ៉ុមជាប់កូនទូចអត់បានទៅធ្វើការអី៕

ក៖ អ៎...ចាំ..ចុះបងកើតកូនប្រហែលជាបានប៉ុន្មានខែហើយបង?

ខ៖ ញ៉ុមបាន...អឺ..កូនញ៉ុមបានប្រាំបួនខែ..

ក៖ អ៎...ចាំ..រៀងរឹងដៃរឹងជើងអ្វើយ...!

ខ៖ ចាំស...!

ក៖ ការកើតនិង....កើតនៅពេទ្យណាដែលបង?

ខ៖ ញ៉ុមកើតពេទ្យរុស្ស៊ី...!

ក៖អ៎...កាលនិងកើតអស់លុយតេសបង?

ខ៖អឺ....ញ៉ុមបានអង្គការគេជួយ...!

ក៖ អង្គការស្អុតអ្វេសបង?

ខ៖ ចាំ...អង្គការស្អុត...!

ក៖ ពេលណា
ពេលដែលយើងមានទុក្ខអីចឹងទៅរកគេអ្នោះណោះបងណោះឈឺស្កាត់អីណោះ?

ខ៖ ចាំ...ដូចថាយើង
ដូចថាខ្វះថវិកាចឹងយើងប្រាកដជាអត់មែនចឹងយើងសំភាសន៍កន្លែងគេចឹងគេអោយមានប័ណ្ណ

រមួយគេហៅប័ណ្ណសមាជិកគេនិង...ចាំ..ហើយពេលយើងទៅពិនិត្យពោះយើងយកកាតនិងទៅគេអត់យកលុយទេព្រោះគេបង្កើតប័ណ្ណនិងគេបង្កើតអោយអត់យកលុយទេ....

ក៖ ចាំ..បងកូនស្រីបងឈ្មោះ ទេបងបានកូនស្រីក៏កូនប្រុស ដែលទើបនិងកើតអ្នាស?

ខ៖ ស្រី...!

ក៖ ឈ្មោះអីគេដែលបង..?

ខ៖ ឈ្មោះ អឺ...ម៉ែន ស្រីនាថ...!

ក៖ ឈ្មោះម៉ែន ស្រីនាថ ទិចទៀតធំរត់លេងពេញនិង ពេញវាលហើយចាំមើល...!
ចុះតើបងចាំសាច់រឿងទាក់ទងទៅនិងបងប្អូនបងទេ
ថាកាលពីក្មេងធ្លាប់ប្រលែងគ្នាមិចខ្លះដែលចឹងអ្នាំស?

ខ៖ ញុំមធ្លាប់ចាំបានថាបងញុំមគាត់បេះអំពិលយកទៅលក់អីចឹងអ្នាស
ដល់ហើយញុំមទៅជួយបេះគាត់ហើយយកមកលក់ចឹងទិញអង្ករហូបអីហូបនៅស្រុក...!

ក៖ លក់តែអំពិលអ្ហេ..ណោះបងណោះអត់មានលក់អីផ្សេងទេ?

ខ៖ បេះអំពិលបេះត្រកួនបេះអីយកលក់តាមនេះតាមស្រុកគេនិងអ្នាសកាល
យើងនៅក្មេងហីយើង...និយាយរួមយើងអត់មានដីស្រែដល់ពេលចឹងទៅយើងអត់មានដូចថា
មុខរបរអីរកអញ្ចឹងហើយយើងនៅក្មេងៗចឹងមានតាដើរបេះអំពិលបេះអីហើយបេះត្រកួនបេះអី
បេះម្អមយកទៅលក់ស្រុកគេ...!

ក៖ ចាំ...បេះចឹងបេះត្រកួនបេះអីចឹងមានជួបឈ្លើជួបអីទេបង?

ខ៖ ចាំ...ជួបតាស...!
រត់រហូតនិង...ហើយពេលឃើញដងហាកូវតាណាមានដង្កូវចឹងរត់រហូតពីរនាក់បងប្អូនប៉ុនមិនដឹងធ្វើមិចទេយើងអត់ហើយ
ចេះតាតស៊ូបេះទៅយើងអត់ទៅហើយលក់យកលុយមកជួយម៉ែជួយអី៕

កៈ
ចាំ...ចុះដូចជានៅពេលកាលបងនៅពីក្មេងអ្នាសតើបងដូចជាចូលចិត្តធ្វើអីជាមួយបងប្អូនរបស់បងឯងអ្នាសចូលចិត្តលេងអីមួយចឹងអ្នាស?

ខៈ
ចាំ..ញ៉ុមចូលចិត្តនេះចូលចិត្តជួយគ្នាដូចថាបើរឿងលេងដូចមិនសូវបានលេងអីទេប៉ុនចូលចិត្តគឺតាចូលចិត្តជួយគ្នាចឹងអ្នាសបែបដូចថាធ្វើនេះធ្វើនោះចឹងអ្នាសជួយគ្នា៕

កៈ អ...បងចូលចិត្តជួយគ្នាច្រើនជាងលេងណោះបងណោះ?

ខៈ ចាំ...

កៈ ចុះឥលូវពួកគាត់រស់នៅទីណាដែរបងប្អូនបងអ្នាស?

ខៈ ពួកគាត់នៅផ្សេងៗគ្នា
ពួកគាត់នៅភូមិនេះដែរគាត់នៅភូមិឬស្សីមួយនៅខាងណោះចឹងទៅមួយនៅដំណាក់ធំ....

កៈ នៅជិតៗគ្នាដែលអ្ហេសណោះបងណោះមិនមែនមាននៅខេត្តផ្សេងៗទេណោះបង?

ខៈ មាន....ខេត្តផ្សេងនៅកំពង់ចាម...

កៈ និងគាត់កូនទីប៉ុន្មានដែលនៅខេត្ត..?

ខៈ និង...បន្ទាប់ពីខ្ញុំ...ប្អូនខ្ញុំ..

កៈ គាត់ទៅកំពង់ចាមធ្វើអី?

ខៈ គាត់អឺ...! មានប្ដីនៅនុងនៅស្រុក...!

កៈ គាត់ប្រកបមុខរបរអីគេដែរនៅនុង?

ខៈ គាត់នេះដែរនិង...ប្ដីគាត់ដែរឡានសំរាមដែរនិង...! គ្នានុងសុទ្ធតាអ្នកអត់ដែរនិង..

កៈ អុំ...ចាំ..គាត់មានគ្រួសារខាងកំពង់ចាមផ្សេង
ចឹងមានតាមួយទេដែរបែកទៅខេត្តកំពង់ចាមក្រៅពីនិងនៅភ្នំពេញទាំងអស់ណោះបង?

ខ៖ ចាំ...! នៅភ្នំពេញទាំងអស់...!

ក៖ ធ្លាប់ជួបជុំគ្នាលេងបុណ្យទានអីទេបង?

ខ៖ ជួនកាល ..ខែបុណ្យជួនកាលអត់សូវបានជួបគ្នាទេ ជួនកាលគេទៅខាងប្ដីគេទៅ ជួនកាលទៅខ្លះម៉ោស្រុកទៅជួបគ្នាម្នាក់ពីរនាក់អីចឹងទៅ អត់សូវបានជួបគ្នាសោះ....

ក៖ ចាំ....បងចាំនិយាយអញ្ចឹងម្ដាយរបស់បងស្រីមានឈ្មោះអីដែរ?

ខ៖ ម្ដាយខ្ញុំឈ្មោះ សឹង ញរ...!

ក៖ សឹង ញរ ចាំ...ចុះម្ដាយរបស់បងគាត់ជាមនុស្សបបណាដែរ?

ខ៖ គាត់និយាយរួមគាត់ស្រលាញ់កូន ហីជួនកាលគាត់ប្រដែរប្រដៅកូនចឹងទៅហើយឥលូវគាត់ចាស់ហើយអាយុជិតហុកសិបហើយគាត់ ហាសិបប្រាំបួនហើយគាត់តែគាត់ទៅរកអេតចាយរកអី ជួនកាលគាត់នៅបែកផ្ទះបែកពីញ៉ុមមែនតែពេលាត់បានស្អីម៉ោចឹងដឹងតាគាត់ម៉ោហើយហៅញ៉ុមអោយយក បានម្ហូបបានអី ព្រោះអីជួនកាលញ៉ុមត់លុយទិញម្ហូបចឹងគាត់អោយលុយសំរាប់ទិញម្ហូបទិញអីអោយយើងហូបជួនកាលគាត់អត់មានមកហូបជាមួយយើងទេតែគាត់ឃើញកូនអត់ចឹងគាត់ចេះតាជួយ...៕

ក៖ ចាំ..គាត់ស្រលាញ់បងឯងមែនទែន ចឹងគាត់ស្លូតបូតទេណេះបងណេះតើគាត់កាចអេ្ហស?

ខ៖ គាត់អត់កាចតេសគាត់ស្លូត...!

ក៖ ចឹងអ្ហោះណោះបងណោះ?

ខ៖ ចាំ...!

ក៖ ចុះឪពុកវិញតើគាត់មានឈ្មោះអ្វីដែរ?

ខ៖ ឪពុកញ៉ុមឈ្មោះ ក្រូច គ្រឿន...!

ក៖ក្រូច គ្រឿន ហ៊ិកហ៊ិក..ឈ្មោះគាត់ដូចអ្នកកំប្លែង

ខ៖ ចា....!

ក៖ តើគាត់មានអាយុប៉ុន្មានហើយ?

ខ៖ គាត់...ឪពុកញ៉ុមគាត់អាយុអឺកអាយុហុកសិបជិតចិត្តសិបហើយហុកជាង...!

ក៖ អ៎...ចា៎..ចុះគាត់មានមុខរបរអីទេសព្វថ្ងៃ?

ខ៖
គាត់នៅផ្ទះនិងគាត់ត់...ជូនកាលគេហៅគាត់ដើរតុការដើរអីចឹងម្ហាសជូនកាលបើកម៉ាស៊ីនបើក
អីជូនកាលទៅ...

ក៖ ម៉ាស៊ីនអីគេដែរបង?

ខ៖ម៉ាស៊ីនអាត្រាក់ ម៉ាស៊ីនកិនស្រូវ គេហៅគាត់..

ក៖ គាត់ចេះ....?

ខ៖ ចា៎..គាត់ចេកាន់ម៉ាស៊ីន
តាមថាគាត់ចេះតាទៅៗព្រោះថានៅស្រែចឹងគាត់អត់មានមុខរបរអីចឹងអកហាស
គេហៅរត់តុការចឹងគេអោយមួយថ្ងៃមួយពោងនិងគេអោយប្រាំម៉ឺនអីគាត់ចេះតាទៅៗ...!

ក៖ ចា៎...បងហើយគាត់ជាមនុស្សបែបណាដែលបងឪពុកបង?

ខ៖ និយាយរួមគាត់នេះដែរ ស្រលាញ់កូនដែរប៉ុនតែថាគាត់ចូលចិត្តហូបស្រាបន្តិច...៕

ក៖ គាត់ចូលចិត្តហូបស្រា...?

ខ៖ ចា៎...គាត់ចូលចិត្តហូបស្រា...

ក៖ អញ្ចឹងពេលដែលគាត់ហូបស្រាម្តងៗមានធ្លាប់វ៉ៃអីបងទេ?

ខ៖ គាត់ធ្លាប់វ៉ៃដែលតាស....!

ក៖ បងឯងខូច..ឬក៏គាត់ស្រវឹងគាត់វង្វេង..?

ខ៖ គាត់ស្រវឹង...គាត់ស្រវឹងអញ្ចឹងទៅ....

ក៖ គាត់ញោះលេងតាអ្វីបង?

ខ៖ គាត់នេះ...គាត់វ៉ៃ...

ក៖ អ៎..គាត់វ៉ៃបងណោះតែបងឯងអត់ខឹងទេ?

ខ៖ ចា៎...ញ៉ុមអត់ខឹងគាត់ទេស ដោយសារ..

ក៖ ព្រោះគាត់ស្រវឹងអីចឹងម្អាស...

ខ៖ ចា៎...ព្រោះគាត់ស្រវឹង...ដល់តាពេលគាត់អត់ស្រវឹងវិញគាត់ស្រួលតេស
ហៅកូនហៅអីចឹងទៅ...

ក៖ គាត់កាចពេលស្រវឹង?

ខ៖ ចា៎...គាត់កាចតាពេលស្រវឹង..

ក៖
ចា៎...គាត់អញ្ចឹងនេះជាមុខរបរគាត់ឥលូវចុះពីមុនគាត់ជា...គាត់មានមុខរបរគាត់ធ្វើអីវិញដែរកាលនៅស្រុកកំណើតអីណាស់?

ខ៖ គាត់កាលនៅស្រុកកំណើតគាត់ធ្វើការអញ្ចឹងដែលនិង...ឥលូវគាត់នៅស្រុកតាស...!

ក៖ ឥលូវនិងគាត់នៅស្រុក?

ខ៖ ចា៎...គាត់នៅស្រុកក៖ តែម្ដាយនៅភ្នំពេញ?

ខ៖ ចា៎..គាត់នៅភ្នំពេញ..ចា៎គាត់បែកគ្នា...

ក៖ អ៎...តែម្ដាយកាលពីមុនគាត់រកមុខរបររកស៊ីអីគេដែរ..?

ខ៖ នេះដែរនិងបេះអំពិល
បេះអីយកលក់ចឹងដូចកូនហើយស៊ីឈ្នួលដកស្ទូងអោយគេចឹងចិញ្ចឹមកូន...ហើយដល់ពេលគាត់ពិបាកពេកនៅស្រុកពេលអស់ទឹកខែវស្សាចឹងអត់មានការងារធ្វើអីអញ្ចឹងគាត់មករកស៊ីនៅភំ

ពេញនិងទៅបានរកអេតចាយទៅហូបប្រចាំថ្ងៃគាត់ចឹងទៅហើយចិញ្ចឹមប្អូនញ៉ុមមីពៅខ្លះអីខ្លះ...

កៈ ចាំ...ចឹងម្នាក់ពៅនិងគាត់មានការងារធ្វើហើយតាអ្វីក៏គាត់នៅរៀន?

ខៈ គាត់ទើបនិងរកការងារធ្វើ រកការងារមិនទាន់បានមួយខែផង គាត់ទើបនិងឈប់រៀនមួយខែនេះដែរដូចថាប្អូនខ្ញុំថាពិបាកពេកម៉ែញ៉ុមគាត់អត់ចឹងហើយយើងត្រូវការលុយទៅរៀនហើយលុយទិញខោអាវទិញពាក្យចឹងដូចថាវាពិបាកចឹងពិបាកលុយទារលុយម៉ែអញ្ចឹងអ្នាសដល់ពេលហើយគាត់ថាគាត់ធ្វើការល្មមៗចឹងទៅអ៎ស...គាត់រៀនតាល្មមៗទៅគាត់ធ្វើការអញ្ចឹងបានជួយម៉ែខ្លះ៕

កៈ អាណិតគាត់អញ្ចហាណេះបងណេះ?

ខៈ ចាំ...

កៈ ទោះជាគាត់រៀនក៏គាត់អត់មានអារម្មណ៍រៀនដោយសារគាត់នៅគិតម្តាយចឹងអីណាស់បង?

ខៈ ចាំ....!

កៈ ចុះឪពុករបស់បងធ្លាប់ប្រាប់បងពីសាច់រឿងកាលគាត់នៅក្មេងអីប្រាប់បងទេ?

ខៈ គាត់ប្រាប់...គាត់ប្រាប់ខ្ញុំតាស..!

កៈ គាត់ធ្លាប់ប្រាប់បងយ៉ាងមិចខ្លះ?

ខៈ គាត់ប្រាប់ថាម៉ែគាត់កាលនៅក្មេងម៉ែគាត់មិនសូវអោយគាត់ពិបាកទេបើគាត់នៅក្មេងម៉ែខាងយាយតួតអស់យាយញ៉ុមអីនិងគាត់មានចឹងអ្នាស មានគោមានអីដល់ទៅអញ្ចឹងគាត់អត់សូវហាត់ទេហើយតាញ៉ុមអីគាត់អឺថាគាត់រកបានរកអីអញ្ចឹងអ្នាសលុយអីមិនខ្វះហូបចុកទេហើយដល់ពេលម៉ោគាត់មានប្តីទៅគាត់ពិបាកតាផឹកនិងប្តីមានកូនគាត់ពិបាករហូត...ដល់ឥលូវគាត់ពិបាកមែនស្រួលទេទៅរើសអេតចាយរហូតនិងឥលូវ...

កៈ ចាំ...ចុះឪពុកម្ដាយរបស់បងធ្លាប់ប្រាប់ទេថាអី
ដូចជាគាត់ឆ្លងកាត់នូវរឿងរ៉ាវទុក្ខលំបាកធំៗអីខ្លះឬក៏គាត់ធ្លាប់ប្រដៅបងឯងថាមិចខ្លះទៅបង?

ខៈ គាត់ចេះតែប្រដៅទៅ
គាត់ប្រដៅថាកុំអោយយើងជក់ថ្នាំកុំអោយយើងលេងល្បែងលេងអីគាត់ចេះតាប្រាប់យើងទៅ
គាត់ប្រាប់ថាកូនអើយកុំលេងល្បែងលេងអីព្រោះយើងក្រចឹងហើយប្ដីរកមិនសូវបានយើងក៏មិនរកអី គាត់ចេះតាប្រដៅយើងអញ្ចឹង
ញ៉ុមអត់ខឹងគាត់ទេព្រោះគាត់ប្រដៅព្រោះមិនចង់អោយយើងអត់ស៊ីអីអញ្ចឹងអ្នាស
ដូចថាគាត់...និយាយរួមគាត់ប្រដៅអោយយើងល្អប៉ុន.ដូចថាបងញ៉ុមគាត់តាលីម៉ែនិយាយអញ្ចឹងគាត់ខឹងបើញ៉ុម
អត់ខឹងគាត់ទេដូចថាគាត់ស្រលាញយើងហើយបានគាត់ប្រដៅយើងអញ្ចឹងអ្ហោះ...!

កៈ បងឯងល្អអ្នាចាំ...ចុះដូចជាយាយតាខាងម្ដាយបងមានចាំឈ្មោះគាត់ទេ?

ខៈ អ៊ឺ...តាញ៉ុំឈ្មោះតាបាន..

កៈ ចុះយាយ...!

ខៈ យាយញ៉ុំឈ្មោះយាយសុង សឺន...

កៈ ចុះខាងឪពុកវិញ?

ខៈ អ៊ឺក...យាយស្អីគេបានទេនាគ..

កៈឈ្មោះកាត់ក៏បាន...!

ខៈ ឈ្មោះតាញ៉ុំឈ្មោះតាបានម៉ងគេហៅតែតាបានតាបានចឹង....!

កៈ ចុះយាយវិញ?

ខៈ យាយញ៉ុមឈ្មោះសឹង សឺនហៅតែយាយសឺនយាយសឺន..!

កៈ ចាំ..និងខាងអីគេបង...?

ខៈ ចាំស...!

កៈ ខាងម្តាយក៏ខាងឪពុក?

ខៈ អឺក...យាយសឺនគាត់ខាង....យាយសឺនខាងម្តាយហើយតាបានខាងម្តាយញ៉ុមដែរបង..៕

កៈចុះយាយតាខាងឪពុកវិញ?

ខៈ ខាងឪពុកអីគេអញ្ចេះ...តាជាហ៊ុយាយប៊ុន....!

កៈ
អំ..តាជាយាយប៊ុន(សើច)៕ចុះតើប៉ាម៉ាក់របស់បងធ្លាប់ប្រាប់បងទាក់ទងទៅនិងរឿងយាយតារបស់បងរអ្វែសដូចថាគាត់កាលគាត់នៅកំលោះរកស៊ីអីគេចរិតបែបណាអីចឹងអ្នាស?

ខៈ
ញ៉ុមធ្លាប់តាលឺពីម៉ាក់ញ៉ុមេពីយាយហើយនិងតាបើពីឪពុកញ៉ុមអត់ដែលលឺទេញ៉ុមដឹងតាពីយាយតាញ៉ុមថាយាយញ៉ុមគាត់ដើរលក់ថ្នាំចឹងទៅអ្នាសហើយគាត់រកបានអ្នាសហើយពីរនាក់ប្តីប្រពន្ធគាត់ស្រលាញ់គ្នាណាស់ហើយតាញ៉ុមអ្នកកាប់ដើមថ្នាំយកអោយយាយញ៉ុមយកទៅលក់ថា...ហើយគាត់មានគោគាត់រកបានទៅមានគោមានអីនៅក្រោមផ្ទះហើយកូនចៅគាត់ទាំងអស់មិនដែរខ្វះស្លៀកពាក់ទេ
ដូចថាគាត់មនុស្សល្មើយចេះស្រលាញ់កូនចឹងម៉ែញ៉ុមគាត់ប្រាប់អញ្ចឹងអ្នាស..៕

កៈ ចុះគាត់មានប្រាប់បងថាយាយតារបស់បងស្លូតរឺក៏កាចអីទេមានវៃម៉ាក់ប៉ាបងអីដែរទេ?

ខៈ
គាត់ថា...ម៉ាក់ញ៉ុមប្រាប់ថាម៉ាក់ប៉ាគាត់អត់ដែរវៃគាត់ផងពួកគាត់អត់ដែរវៃគាត់ជួនកាលគ្រាន់តាគាត់ថាអោយមួយម៉ាត់ពីម៉ាត់ទេតែគាត់មិនដែរវៃកូនទេ...និយាយរួមគឺអត់ដែរលឺម៉ែគាត់ថាម៉ាក់គាត់វៃគាត់ទេ...!

កៈ អញ្ចឹងបានម៉ាក់បងស្លូតតទៀត?

ខៈ ចាំ...គាត់ស្លូត..

កៈ ប៉ាក៏ស្លូតលុះត្រាណាគាត់ស្ររឹង?

ខ៖ ចាំ..!

ក៖ ចុះដូចជាតើដូចជាក្រុមគ្រួសាររបស់បងម្ចាស់តើមានដូចជាបងប្អូនរបស់បងមួយណាទៅធ្វើការងារនៅក្រៅប្រទេសទេ?

ខ៖ អត់មានផង..!

ក៖ ពួកគាត់សុទ្ធតានៅប្រទេសខ្មែរទេណោះបងណោះ?

ខ៖ ចាំ...នៅខ្មែរទាំងអស់...!

ក៖ ឥលូវចូលទៅដល់ស្វាមីរបស់បងវិញ ថាតើស្វាមីរបស់បងមានឈ្មោះអ្វីដែរ?

ខ៖ អឺក ...ម៉ែន ពន្លក...

ក៖ ម៉ែន ពន្លក...?

ខ៖ ចាំស...!

ក៖ ចុះគាត់មានមុខរបរអីគេដែរ?

ខ៖ គាត់មានមុខរបរដូចជា ពេលថ្ងៃគាត់ធ្វើសន្តិសុខមកពីធ្វើសន្តិសុខវិញជូនកាលគាត់រើសអេតចាយដើម្បីទិញម្ហូបរាល់ប្រចាំថ្ងៃទម្រាំញ៉ុមបើកប្រាក់ខែ...!

ក៖ គាត់អាយុប៉ុន្មានហើយបង?

ខ៖ គាត់ឆ្នាំថោះប្រហែល..គាត់ឆ្នាំថោះប្រហែលសាមពីរហើយ...!

ក៖ ចាំស...ចាំបងចុះបងឯងមានកូនប៉ុន្មាននាក់?

ខ៖ ញ៉ុមកូនបីនាក់...!

ក៖ ស្រីប៉ុន្មានប្រុសប៉ុន្មានទៅបង?

ខ៖ ញុំមស្រីពីរប្រុសមួយ៕

ក៖ ចាំ...ឈ្មោះអីគេខ្លះបង?

ខ៖ ប្រុសអឺក...ឈ្មោះ ម៉ែន ប្រុសពេជ្រ ហើយស្រីទីពីរឈ្មោះម៉ែន លីហ្សា និងទីបីឈ្មោះម៉ែន ស្រីនាថ...

ក៖ អូ...ឈ្មោះសុទ្ធតែពិរោះៗបងណោះ...! ៕ចុះតើបងមានបង្កើតគម្រោងសំរាប់គាត់ដូចថាបើសិនជាគាត់ធំបងបញ្ជូនគាត់ទៅរៀនអោយអស់អីអ ៗអញ្ចឹងអឺណាស់មានគម្រោងសំរាប់គាត់អីចឹងអ្នាស?

ខ៖ រាល់ថ្ងៃខ្ញុំកំពុងសុំខាងអង្គការអោយអង្គការគេបញ្ជូនកូនទៅរៀនអោយគេជួយលីហ្សាតែបើប្រុសពេជ្រគេទៅខាងភាពញញឹមហើយឆ្លើយចឹងនៅលីហ្សា ព្រោះលីហ្សាគាត់កើតឆ្នាំពីរពាន់ដប់បីឥលូវប៉ុន្មានគាត់ប្រាំឆ្នាំជាងហើយ...

ក៖ ចាំ...!

ខ៖ ប្រាំឆ្នាំជាងហើយគាត់...

ក៖ ចាំបង...ចុះបងរៀបអាពាហ៍ពិពាហ៍ដោយចិត្តស្រលាញ់គ្នាផ្ទាល់ឬក៏ដោយឪពុកម្តាយជាអ្នករៀបចំអោយ?

ខ៖ ចាំស..? ញុំមស្រលាញ់គ្នាផ្ទាល់...

ក៖ បងជួបគ្នាដំបូងនៅទីណាដែរបង?

ខ៖ នៅភ្នំពេញ...(សើច)

ក៖ ពេលនិងបងកំពុងធ្វើអីគេដែរ?

ខ៖ ញុំមធ្វើខាងនេះ...អ៊ីក ដូចថាគេរកម៉ោយើងដូចថាអ្នកប្រាប់គេអោយដាក់ជ័រ
ដូចថាខាងជ័របែងចែកជ័រឆ្អើណាស់គ្រូបាច់ចែកពណ៌ អូស្សូន
ខាងបេការអីនិងចាំ..ហើយជួបគាត់នៅអីម្តុំផ្ទះចាស់ញុំមជួលកាលនៅឯណាំក....

ក៖ ទៅដល់ពេលជួបគ្នាពេញចិត្តគ្នានិងវិញទៅម៉ោទៅណោះបងណោះ?

ខ៖ ចាំ...!

ក៖ ហើយចុះបងរៀបការតាំងពីឆ្នាំណាម៉ោ?

ខ៖ ពីឆ្នាំពីរពានប្រាំមួយអ្ហោះ...!

ក៖ នាំពីរពានប្រាំមួយ...?

ខ៖ ចាំ..!

ក៖ ច្រើនឆ្នាំហើយ...! ដប់ពីរឆ្នាំហើយ..!

ខ៖ ចាំ...ដប់ពីរឆ្នាំហើយ..!

ក៖ ចាំ...! ប្តីរបស់បងគាត់គឺជាមនុស្សបែបណាទៅបង?

ខ៖ មនុស្សស្លូតហើយស្រាក៏អត់ចេះហូប បារីក៏គាត់អត់ចេះជក់
ដែរហើយស្រីញីអីក៏គាត់អត់ចេះនេះដែរត់ចេះមានដែរ..!

ក៖ ចាំ...អញ្ចឹងប្តីរបស់បងគាត់រៀនបានថ្នាក់ទីប៉ុន្មានដែរបង?

ខ៖ គាត់ថា....រៀននៅភាពញញឹមគាត់ថារៀនដល់ជំនាញហើយប៉ុនណាគាត់បានរៀនត...

ក៖ ចាំ...បង.!
បងបានប្តីល្អមែនទែនចុះបង...ថ្លៃជំនូនវិញបងតើបងទទួលបានថ្លៃជំនូនប៉ុន្មានដែរបង?

ខ៖ ដូចអត់នេះផង..ដូចថាៗយើងអត់ដូចគ្នា...

ក៖ បងអត់ដូចគ្នា...អញ្ចឹងមានប៉ុនណាយើងធ្វើប៉ុននិង...

ខ៖ ចាំ..និងហើយ

ក៖
ចាំ...ដូចជាសំរាប់បងអ្នាសតើបងដូចជាប្តីរបស់បងដូចថាក្តីស្រលាញ់រវាងបងនិងប្តីរបស់បងអ្នាសមានទំហំប៉ុនណាទៅ?

ខ៖ និយាយរួម....

ក៖ ដូចថាធ្លាប់ឈ្លោះគ្នាប្រកែកគ្នាវៃគ្នាអីទេ?

ខ៖
អត់នេះអ្ហែ...និយាយរួមគាត់អត់ដែរវៃញុំមទេតាំងពីបានគ្នាមកគាត់អត់ដែរវៃ...ប៉ុនមានប្រកែកគ្នាមានអីខ្លះ ប៉ុនប្រកែកគ្នាមិនបានប៉ុន្មានទេត្រូវគ្នាវិញហើយ
មិនបានប៉ុន្មានត្រូវគ្នាវិញទៀតទៅ៕

ក៖ ចាំ..ដោយសារបងឯងស្រស់មែនទែនអញ្ចឹងប្តីរបស់បងអត់ហ៊ានឈ្លោះយូរទេ
ព្រោះប្រពន្ធញញឹមស្រស់អ្នាំស៕ចាំ...បងចឹងរៀន...បងអត់បានរៀនសូត្រទេណេះបងណេះបង?

ខ៖ ញុំមរៀនបានត្រឹមថ្នាក់ទីប្រាំ...

ក៖ យី...ទីប្រាំដែរតាំសបង?

ខ៖ ចាំ..!

ក៖ អានអក្សរដាច់និងសរសេរអក្សរបានហើយ?

ខ៖ ចាំស..!

ក៖ ចុះបងមានចេះភាសាអីផ្សេងទៀតទេ?

ខ៖ ញុំមអត់..! ចេះតាភាសាខ្មែរ...!

កៈ អ៎..ចេះតែភាសាខ្មែរទេ..! ចឹងបងអាចមានចំណេះមួយនិងអាចជួយកូនអញ្ចឹងអ្នាសដូចថាពេលខ្លះកនបងអត់ចេះសរសេរកន្លែងនិងអញ្ចឹងបងអាចបង្រៀនគាត់ថែម...!

ខៈ ចា៎..!

កៈ តើដូចជាបងរៀនថ្នាក់ទីប្រាំនិងនៅសាលាបឋមសិក្សាណាដែរបង?

ខៈ នៅសាលាបឋមសិក្សាព្រៃឈរ...

កៈ នៅសាលាបឋមសិក្សាព្រៃឈរ...នៅឯស្រុកអ៎..បង?

ខៈ ចា៎..នៅឯស្រុក..!

កៈ ចា៎បង..ចុះមូលហេតុអីបានជាបងឈប់រៀនដែរបង?

ខៈ ញ៉ុមដោយសារគ្រួសារញ៉ុមពិបាកពេកដូចថាម៉ែឪញ៉ុមនៅឯស្រុកគាត់អត់មានការងារអីធ្វើហើយញ៉ុមឃើញប្អូនញ៉ុមគាត់ឈឺហើយដល់ពេលចឹងទៅញ៉ុមឃើញពិបាកពេកញ៉ុមក៏...ដល់ពេលគេមករកមនុស្សនៅជាមួយគេទៅជួយគេលក់ដូរអញ្ចឹងទៅញ៉ុមក៏ដាច់ចិត្តចេញទៅៗ...

កៈ ទៅឈប់រៀនទៅនៅជាមួយគេ...

ខៈ ចា៎...! ញ៉ុមឈប់រៀន..

កៈ ទៅនៅជាមួយគេលំបាកទេបង?

ខៈ ចា៎..លំបាកដែរដូចថាៗគេមិននេះដូចយើងអញ្ចឹង...ដូចថាវាមិនដូចកាលយើងនៅផ្ទះយើងអញ្ចឹង...

កៈ វាមិនដូចយើងនៅផ្ទះខ្លួនយើងទេចា៎...បងហាត់នឿយខ្លាំងណោះបងណោះ?

ខៈ ចា៎...ដោយសារ..

កៈ ចាំក្រៅពីទៅនៅជាមួយគេបងមានប្រកបមុខរបរអីផ្សេងទៅទៀតទេ?

ខៈ ញ៉ុមអត់ផង...

កៈ អត់ទេណោះបងណោះ?
ចាំ..ដូចជាកាលបងរៀននៅបឋមសិក្សានិងតើបងមានមិត្តសម្លាញ់អីនៅទីនោះទេ?

ខៈ នៅស្រុកមាន...ប៉ុនឥលូវបែកគ្នាអស់ហើយ...

កៈ តែបើជួបគ្នាស្គាល់...? គេមានគ្រួសាររបស់គេណោះបងណោះ..!

ខៈ ចាំ.ប៉ុនឥលូវមិនដែរស្គាល់គ្នាផង...មិនដឹងគេនៅ...

កៈ ក្មេងៗពេកពេលនិង..?

ខៈ
ចាំ...និយាយរួមធំៗដែរប៉ុន្តែឥលូវភ្លេចនេះហើយដូចថា..រាប់ឆ្នាំហើយយើងភ្លេចមុខគ្នាអស់ហើយ..៕

កៈ
ចាំ..បងចុះតាំងពីបងនៅក្មេងអ្នាសជីវភាពតាំងពីបងនៅក្មេងហើយនិងជីវភាពរបស់បងឥលូវនិងបងគិតថាមានការផ្លាស់ប្តូរអីទេ?

ខៈ ញ៉ុមគិតថា...

កៈ ពិបាកដូចគ្នាឬក៏មានការស្រួលជាងមុនហើយ...

ខៈ
ដូចថាយើងពិបាក...វាដូចជាមិនពិបាកដូចមុនដូចថាឥលូវយើងមានប្តីមានអីគ្រាន់យើងរកស៊ីទោះយើងជំពាក់គេក៏យើងវារៀងស្រួលជាងពីមុនដែរព្រោះពីមុនយើងពិបាកអ្នាំ...ជួនកាលយើងរកអត់បានអត់មានអីហូបទេនៅផ្ទះដើរជំពាក់ខ្ញីអង្ករអីខ្ញីអីគេហូបម៉ែញ៉ុមនិយាយទៅគួរអោយអាណិតគាត់អ្នាំ..

កៈ និយាយទៅអោយតែចិញ្ចឹមជីវិត...!

ខ៖ ចាំ....!

ក៖ ចាំ..ឥលូវយើងមកបង់វែអារម្មណ៍វិញបង...ថាតើបងបងចូលចិត្តមុខម្ហូបអីគេដែរបង?

ខ៖ ញ៉ុម...បើញ៉ុមចូលចិត្តអឹក...ម្ជូរគ្រឿងចាំ...

ក៖ ម្ជូរគ្រឿងណោះបងណោះ?

ខ៖ ចាំ...!

ក៖
ចុះល្បែងប្រជាប្រិយ៍វិញកាលបងនៅពីក្មេងអ្នាសមានចូលចិត្តលេងល្បែងប្រជាប្រិយ៍ពេលបុណ្យទានអីផ្សេងៗអ្នាសបងចូលចិត្តលេងអីគេដែរ?

ខ៖ ញ៉ុមចូលចិត្តអឹក លេងលោតអន្ទាក់...!

ក៖ អ់..លេងកៅស៊ូនិងមែនបង?

ខ៖ ចាំស...!

ក៖ បងឯងដូចញ៉ុមបេះបិតហើយបងអើយញ៉ុមចូលចិត្តលេងកៅស៊ូរហូត...

ខ៖ ចាំ...ញ៉ុមចូលចិត្តលេងហាក់...

ក៖
ញ៉ុមនិងស្អតាកំពូលលេងកៅស៊ូហើយហាក់អន្ទាក់ហាក់អីនិងសូក្កឡាបង់បងអីនិងសុទ្ធតែរបស់ញ៉ុមទាំងអស់...អញ្ចឹងបងចូលចិត្តលេងកៅស៊ូណោះបងណោះ?

ខ៖ ចាំ...!

ក៖ រាំវង់រាំក្បាច់អីបងចេទេ?

ខ៖ ញ៉ុមចេះតាសរាំវង់ហ៊ីអឹក...រាំវង់ហើយនិងសារ៉ាវ៉ាន់អីនិង...

ក៖ ចុះរាំអញ្ចេកអីបងចេះទេ?

ខ៖ អត់...(សើច)អត់ចេះតេសនិយាយរឿងរាំញ៉ាក់អត់ចេះបណ្តោយរឹងៗខ្លួន...

ក៖ បើថារាំវង់រាំក្បាច់ខ្មែរប្រពៃណីអីចេះ

ខ៖ ចាំ...! រាំញ៉ាក់អត់ចេះម៉ង៕

ក៖ ចុះបង...រឿងចំរៀងវិញតើបងចូលចិត្តចម្រៀងបងណាវិញបង?
បទបុរាណឫក៏បទសម័យ? ហើយច្រៀងដោយអ្នកណាគេដែរ?

ខ៖ ញ៉ុម...ឥលូវដូចជាអី..? ពេជ្រ សោភា...

ក៖ អ៎..បទសម័យៗនេះដែរទេណោះបងណោះ?

ខ៖ ចាំ...!

ក៖ បងចូលចិត្តបទពេជ្រសោភា....ចុះបងចូលចិត្តបទញ៉ាក់ឬក៏បទស្លូដែរបង?

ខ៖ ញ៉ុមចូលចិត្តបទកំសត់...។

ក៖ បទកំសត់ណោះបងណោះ?

ខ៖ ចាំ...!

ក៖ ហ៊ឺ...ស្តាប់បទញ៉ាក់ខ្លះទៅបង...

ខ៖ (សើច)ញ៉ុមចូលចិត្តតែបទកំសត់...

ក៖ ដូចជានៅក្នុងគ្រួសាររបស់បងមានអ្នកណាចេះលេងភ្លេងអីទេបងប្អូនអ្នាស?

ខ៖ អត់មានផង...!

ក៖ អត់មានទេណាំស...បងណោះ?

ខ៖ ចាំ..!

កៈ
ចុះផ្ទះរបស់បងកាលនៅស្រុកអ្នាស..មានស្ថានភាពបែបណាដែរដូចថាផ្ទះរបស់បងឯងទូចឬធំ
?

ខៈ
ផ្ទះរបស់ញ៉ុមកាលនៅស្រុកពីមុនម៉ោវាទូច...ទូចហើយវាពុបាកទៀតនិយាយរួមវាពិបាកម៉ងអ្នាំសនិយាយរួមកាលនៅឯណុងជួនកាលខ្យល់ម៉ោខ្លាំងចឹងវារលំផ្ទះរលំអីធ្វើតាខ្លួនឯង....!

កៈ អឺ...អញ្ចឹងផ្ទះនៅស្រុកនិងដីនិងលក់ហើយចែកកេរ្ត៏ហើយអស់ហើយ?

កៈ នៅទុក្ខនុងឯងចុះអ្នកណាអ្នកនៅនុងដែរបង?

ខៈ ឪពុកញ៉ុមគាត់នៅនុង...!

កៈ អូ...គាត់នៅជាមួយអ្នកណាគេដែរ?

ខៈ គាត់នៅម្នាក់ឯង...!

កៈ អំ...គាត់អផ្សុកណាស់មើលទៅចាំញ៉ុមរកទៅលេងគាត់...

ខៈ (សើច) គាត់នៅតាម្នាក់ឯងនុង។

កៈ អញ្ចឹងពេលទំនេរញ៉ុមទៅលេងហើយណាស់បង
ហើយញ៉ុមថាបងស្រីអោយញ៉ុមមកសួរសុខទុក្ខ..(សើច)។

ខៈ ញ៉ុមឧស្សាហ៍តេទៅលេងគាត់ដែរតាស...

កៈ ចាំ...បងដោយសារគាត់នៅតាម្នាក់ឯង។
ចុះដូចជាផ្ទះរបស់បងនៅស្រុកនិងឪពុកម្ដាយអ្នកសាងសង់ឬក៏...?

ខៈ អឺក...ឪពុកញ៉ុម..

កៈ ចាំ.បងអញ្ចឹងឪពុករបស់បងគាត់ចេះសាងសង់ផ្ទះ?

ខៈ ចាំ...!

ក៖ ចុះបងមានចេះជំនាញអីផ្សេងទៀតទេដែរថាតវេនពីឪពុកម្តាយមកអ្នាស មិនថាម្ហូប មិនថាល្អី ផ្តៅដែរថាបងឯងចេះជាជំនាញមួយពីឪពុកម្តាយចេះមានទេបង?

ខ៖ ញុំមចេះតាសួរ...!

ក៖ ចេះសួរណោសបងណោះ? បងសួរឆ្ងាញ់ហើយមើលទៅចាំថ្ងៃណាមកភ្លក់...។ ចុះតើបងមានបញ្ហាអីទៀតទេដែរបងធ្លាប់ឆ្លងកាត់ការទុក្ខលំបាកដែរនៅជាមួយគេវាបែបណា ឬក៏បន្ទាប់ពីនិងបងបានទៅធ្វើអីទៀតហើយការងារនេះវាធ្ងន់បែបណាចឹងអឺណាស់បងអាចចែកចាយបានទេ?

ខ៖ ទុក្ខលំបាកដូចថាកាលនៅជាមួយគេវាលំបាកអ្ហ៎..ដូចថាកន្លែងនិងគេនិងសារនិងអត់នេះទៀតអត់មានទឹកទេ ណ៎កយើងទៅនេះបញ្ចេកងទៅដួសទឹកពីអីណោះម៉ោយកមកអោយដាក់ពាងគេអ្ហោះហាត់ណាស់ ដូចថាកាលនៅខាងណោះគេហៅស្រែណាយស្រែណាយមិចគេនោះសៀមរាប...

ក៖ ស្រែណាយ...

ខ៖ ចា៎..ស្រែណាយគេនិងនៅឆ្ងាយពីផ្ទះយកម៉ោដងដាក់ពាងគេពេញចឹងទៅបានបោកខោអាវបានអីអោយគេតអីអញ្ចឹងយើងនៅជាមួយគេពិបាកណា៎សវា...និយាយរួមយើងទៅធ្វើការយើងទៅយកលុយគេវាទម្រាំបានវាពិបាក...

ក៖ ចា៎..បងនិយាយទៅបញ្ហាក្រពះនិងគឺវាទាមទារអោយយើងហាត់នឿយខ្លាំងចឹងតែម្តងណោះបង?

ខ៖ ចា៎...!

ក៖ អញ្ចឹងតល្វនិងដូចជាបងមានក្តីស្រមៃកាលនៅពីក្មេងទេដូចថាបងធ្លាប់ចង់ដូចជាមានមុខជំនួ

ញអីអញ្ចឹងឬក៏បងចង់មានគ្រួសារបែបនេះៗឬក៏ចង់ក្លាយជាគ្រូពេទ្យអីៗឬក៏គ្រូបង្រៀនអីចឹង អ្ហ៎ស?

ខ៖ ញ៉ុមកាលនៅពីក្មេងមិញនិយាយរួមញ៉ុមចង់ធ្វើគ្រូបង្រៀន...!

ក៖ គ្រូបង្រៀន..ណោះបងណោះ...!

ខ៖ ចា៎...!

ក៖តែដោយសារជីវភាពយើងអត់បានសម្រេចវាបាន...

ខ៖ ចា៎...!

ក៖
ចឹងអត់អីដោយសារបងនៅមានកូនបងឯងជំនាន់កូនបងឯងទៀតអញ្ចឹងបងឯងអាចប្រាប់គាត់ថាណោកម្ដាយចង់ធ្វើគ្រូបង្រៀនតែម្ដាយធ្វើអត់បានសម្រេចទេកូនឯងជួយសម្រេចអោយផង..(សើច)ចា៎..ដូចជាលើកទឹកចិត្តបងអោយបងអោយកូនរៀនអោយបានខ្ពង់ខ្ពស់បងណា៎..ដើម្បីអោយគាត់អាចដូចជាស្នងក្តីស្រមៃរបស់បងបើមិនអញ្ចឹងទេគាត់អាចខ្ពស់ជាងនិងរកការងារល្អាងមួយនិងមួយនិងទៀត។
អញ្ចឹងដូចជាពួកយើងចង់អោយបងផ្ដែផ្ដាំពាក្យពេចន៍ទូន្មានខ្លះៗទៅកាន់ក្មេងជំនាន់ក្រោយដូចជាកូនចៅរបស់បងផងដែរអញ្ចឹងបងទូន្មានថាមិចដែរ?

ខ៖ ញ៉ុមដូចថាចង់ប្រាប់គាត់ថា...អោយធំឡើងអោយគាត់ខំរៀនសូត្រចឹងអ្ហាស ចា៎អោយគាត់ខំប្រឹងរៀនសូត្រដើម្បីកុំអោយដូចញ៉ុមចឹង...អ្ហូកដូចថាញ៉ុមអត់សូវរៀនបានច្រើនអញ្ចឹងឃើញវាពិបាកវេទនាដូចថាយើងវារៀនបានតិចតួចយើងវាចង់ធ្វើការអីក៏អត់កើតដែរ...ដូចចឹងញ៉ុមចិត្តញ៉ុមដូចថាឥលូវចង់តែថាអោយកូននិងបានចូលរៀនបានអីចឹងកុំអោយអី...អោយមានការងារល្អកុំអោយដូចខ្ញុំកុំអោយពិបេកពិបាកដូចញ៉ុម...ចា៎..រាល់ថ្ងៃញ៉ុមគិតអញ្ចឹងហើយញ៉ុមគិតថាបើបានសុំគេបានចឹងញ៉ុមអត់អោយកូនញ៉ុមដូចថារើសអេតចាយរើសអីទេអោយខំតារៀនពន្យល់គាត់អោយខំប្រឹងគាត់ខំរៀនអញ្ចឹង...

ក៖ ចា៎...លើកទឹកចិត្តគាត់អីចឹង...

ខ៖

ចាំ...លើកទឹកចិត្តគាត់..រាល់ថ្ងៃអ្នាសទោះគាត់កាន់បិចអ្នាសក៏ញ៉ុមឃើញគាត់សរសេរក្រវ៉េមក្រវ៉ាមមិចក៏ញ៉ុមសរសើរគាត់ថាគាត់និងសរសេរស្អាតអីចឹងអីណាស់..អោយគាត់ខំប្រឹងនេះ..ដល់ពេលយូរៗទៅគាត់រៀងសាំដៃអញ្ចឹងគាត់ចឹងពេលចូលរៀនគាត់រៀងសរសេរស្អាតជាងគេ...

ក៖

ចាំ...លញអមែនទែនដូចជាការលើកទឹកចិត្តរបស់ឪពុកម្តាយគឺវាមានសារៈសំខាន់ដោយសារបងមានឱកាសដើម្បីរៀនតែឥលូវមានអង្គការច្រើនហើយអង្គការគេជួយអញ្ចឹងអ្នាសលើកទឹកចិត្តអោយបងប្រគល់គាត់អោយអង្គការដើម្បីអោយអង្គការ...មិនមែនយើងប្រគល់គាត់ទៅអោយទេចង់និយាយថាប្រគល់អោយគាត់មានឱកាសរៀននៅក្នុងអង្គការគេអាចជួយគាត់ច្រើនចឹងអ្នាស...ទាក់ទងទៅនិងភាសានិងដើម្បីបញ្ចប់ថ្នាក់ខ្មែរយើងហើយទៅរៀននៅសកលវិទ្យាល័យអ្វីបែបនិង...អញ្ចឹងពួកយើងមានតែប៉ិននិងប៉ុន្តែពួកយើងសូមថ្លែងអំណរគុណដល់បងម្តងទៀតដែលបងអាចចំណាយពេលវេលារបស់បងដើម្បីបងជជែកលេងជាមួយនិងពួកយើងទាំងអស់គ្នាទាក់ទងទៅនិងជីវិតរបស់បងផ្ទាល់ផងដែរហើយខ្ញុំដឹងថាបងឆ្លងកាត់នូវរឿងរ៉ាវជាច្រើនមែនទែនហើយរឿងរ៉ាវទាំងអស់នោះនិងវាធ្វើអោយបងលំបាកច្រើនហើយញ៉ុមដូចជាជូនពរអោយបង...អោយជីវិតគ្រួសាររបស់បងមានភាពរីកចំរើនជាងមុនហើយជូនពរអោយបង...អោយជីវិតគ្រួសាររបស់បងមានភាពរីកចំរើនជាងមុនហើយជូនពរអោយបងមានសុខភាពល្អកូនរបស់បងប្រកបទៅដោយចំណេះដឹងគាត់មានចំណេះចេះស្ទាត់គាត់ចង់ទៅរៀនសូត្រគាត់មានដុងមួយថាគាត់ចង់រៀនហើយរៀនបានខ្ពង់ខ្ពស់មានការងារល្អធ្វើហើយបងលែងហត់នឿយដូចមុនទៀតហើយពួកយើងដូចជាសុំការអនុញ្ញាតពីបងដើម្បីដាក់សំលេងរបស់បងចូលទៅក្នុងគេហទំព័ររបស់ពួកយើងដើម្បីអោក្មេងៗក៏ដូចជាកូនរបស់បងបានស្តាប់លឺនូវសំលេងរបស់បងតើបងយល់ព្រមដើម្បីអោយពួកយើងអាចដាក់?

ខ៖ ចាំ...អត់អីទេអឹក

..ញ៉ុមយល់ព្រមតាសញ៉ុមសប្បាយចិត្តបានអ្នកគ្រូម៉ោសំភាសន៍អញ្ចឹង...ព្រោះអីដូចថាយើងបានបញ្ចេញយោបល់រឿងដើម្បីអនាគតកូនយើង...។

កៈ

ចាំ..អរគុណណាស់ហើយខ្ញុំសង្ឃឹមថាការជជែកលេងមួយនេះធ្វើអោយបងថូរស្រោលជាងមុនក្នុងអារម្មណ៍ហើយអារម្មណ៍ល្អណាស់បងណាស់អញ្ចឹងពួកយើងមានតែប៉ុននិងហើយសូមជំរាបលាណាបងស្រី...

ខៈ ចាំស...!